# ការបំពាក់បំប៉នជំនួយការសាលាថ្ងៃអាទិត្យ 2006

*គោលការណ៍ នៃការសិក្សា និងការបង្រៀន*

គោលបំណងសំខាន់ៗនៃការសិក្សាដំណឹងល្អ និងការបង្រៀននៅក្នុងសាសនាចក្រ និងនៅផ្ទះ គឺដើម្បីជួយអភិវឌ្ឍន៍សក្ខីភាពអំពីព្រះយេស៊ូវគ្រីស្ទ ហើយនឹងជួយពង្រឹងដល់ក្រុមគ្រួសារ ។ ការយល់ដឹង និងការប្រតិបត្តិតាមគោលការណ៍ដំណឹងល្អនឹងជួយគ្រូបង្រៀន អ្នកដឹកនាំ និងឪពុកម្តាយ មានប្រសិទ្ធិភាពច្រើនក្នុងការអនុវត្តន៍នូវការទទួលខុសត្រូវដ៏ពិសិដ្ឋរបស់ពួកគេ ។

1. " នោះអាចបានព្រះបន្ទូលនៃព្រះ" ( ហេលេមិន 3:29) ។ ការបង្រៀនដំណឹងល្អ និងការសិក្សាមានប្រសិទ្ធិភាព នៅពេលចំណុចសំខាន់ នៅលើគោលលទ្ធិ និងគោលការណ៍នៃដំណឹងល្អ បានស្តារឡើងវិញ នៅពេលដែលពួកគេបានរកឃើញនៅក្នុងព្រះគម្ពីរ ការបង្រៀននៃព្យាការីថ្ងៃចុងក្រោយ ការបោះពុម្ពរបស់សាសនាចក្រ និងតាមរយៈការបំផុសគំនិតនៃព្រះវិញ្ញាណបរិសុទ្ធ ។ ( សូមមើល អាលម៉ា 31:5, យ៉ូហាន 1:1, ហេលេមិន 5:12, គ និង ស 11:21, គ និង ស 52:9 , គ និង ស 18:34-36, អាលម៉ា 32:21, អាលម៉ា 37:11, រ៉ូម 10:17, *សៀវភៅណែនាំការបង្រៀន* ទំព័រ 5)

2. **" ផ្សព្វផ្សាយដំណឹងល្អរបស់យើងដោយព្រះវិញ្ញាណ"** ( គ និង ស 50:14) ។ សារៈសំខាន់ និងការបង្រៀន ការសិក្សាដោយប្រសិទ្ធិភាពបំផុត និងការបីបាច់ថែរក្សាដែលកើតឡើងនៅសាសនាចក្រ ឬនៅផ្ទះគឺជាអ្វីដែលមានទំនាក់ទំនងទៅនឹងបុគ្គលតាមរយៈ អនុភាពនៃព្រះវិញ្ញាណបរិសុទ្ធ ។ ( សូមមើល យ៉ូហាន 14:26, គ និង ស 42:14, គ និង ស 46:2, គ និង ស 46:8-9, អាលម៉ា 17:2-3, គ និង ស 84:85 និង*សៀវភៅណែនាំការបង្រៀន* ទំព័រ 5-6 ។)

3. **" ចូរស្វែងរកការរៀនសូត្រ គឺដោយសារការសិក្សា និងដោយសារសេចក្តីជំនឿផង"** ( គ និង ស 88:118) ។ នៅក្នុងការបន្ថែមដើម្បីមាន "សង្ឃឹមទៅលើអ្វីៗដែលមើលមិនឃើញ ហើយពិត" ( អាលម៉ា 32:21 ) សេចក្តីជំនឿក៏ជា "គោលការណ៍នៃការធ្វើសកម្មភាព" ( *ការបង្រៀននៃសេចក្តីជំនឿ* ការបង្រៀន 1:9) ។ ការបង្រៀនដោយបំផុសគំនិត និងការសិក្សាដែលបានសំរេចល្អបំផុត នៅពេលទាំង គ្រូបង្រៀន និងអ្នកសិក្សារស់នៅ និង *ធ្វើតាម* គោលលទ្ធិ និងគោលការណ៍ដែលបានកំពុងបង្រៀន ។ ( សូមមើល យ៉ូហាន 7:17, គ និង ស 88:77, នីហ្វៃទី2 25:23, អាលម៉ា 32:27, ហេលេមិន 15:7, នីហ្វៃទី3 27:21-22, អេធើរ 2:16-25, 3:1-6 និង*សៀវភៅណែនាំការបង្រៀន* ទំព័រ 6-7 ។)

<u>**ការផ្លាស់ប្តូរការទទួលខុសត្រូវនៅក្នុងសាលាថ្ងៃអាទិត្យ**</u> ( សំបុត្រពី ប្រធាន បិយយេ ផាកកឺ )

- "ដោយប្រសិទ្ធិភាពភ្លាមៗ គ្រូបង្រៀនធ្វើឱ្យអ្នកសំរបសំរួលស្រួលឡើងនឹងធ្វើកិច្ចការក្រោមការណែនាំ នៃគណៈប្រធាន សាលាថ្ងៃអាទិត្យជំនួសឱ្យក្រុមប្រឹក្សាក្នុងគណៈប៊ីស្សព ។ " (3/24/03)
- " ប្រធានវួដសាលាថ្ងៃអាទិត្យនៅតែបន្តជាសមាជិកនៃក្រុមប្រឹក្សាវួដ ។ គ្រូបង្រៀនធ្វើឱ្យអ្នកសំរបសំរួលប្រសើរឡើងនឹងមិនចូលរួមការប្រជុំការប្រឹក្សារបស់វួដទេ ។" (12/05/03)

- " គណៈប្រធានសាលាថ្ងៃអាទិត្យធ្វើការជិតដិតជាមួយបព្វជិតភាព និងអ្នកដឹកនាំអង្គការជំនួយដែលបន្តទទួលខុសត្រូវសំរាប់គ្រូ បង្រៀន អភិវឌ្ឍន៍នៅក្នុងការរៀបចំរបស់ពួកគេ ។" (12/05/03)

**<u>ការប្រតិបត្តិ: ការដឹកនាំ និងការគាំទ្រដែលកំពុងកើតមានឡើង</u>**

- " វួដ [សាខា] បព្វជិតភាព និងអ្នកដឹកនាំអង្គការជំនួយ....ជួបបុគ្គលម្នាក់ៗជាមួយរាល់ការហៅជាគ្រូបង្រៀនថ្មីៗ ដែលគួរឱ្យចូលចិត្តជាងពីមុនថ្នាក់ដំបូងរបស់គ្រូបង្រៀន ។" ( *ការណែនាំ ក្បួនច្បាប់នៃសាសនាចក្រ* 2:305)
- " ពួកគេឱ្យការគាំទ្រដែលកំពុងកើតមានឡើងទៅគ្រូបង្រៀននៅក្នុងការរៀបចំ ។ ពួកគេទាក់ទងគ្រូបង្រៀនម្នាក់ៗយ៉ាងហោចណាស់រាល់បីខែម្តង...." ( *ការណែនាំក្បួនច្បាប់នៃសាសនាចក្រ* 2:305-306)

"រាល់អង្គការជំនួយទាំងអស់ នៃសាសនាចក្រ សាលាថ្ងៃអាទិត្យគឺពិសេស. . . ។ វាគឺជាកម្មវិធីគ្របទាំងស្រុងលើវិសាលគមន៍នៃដំណឹងល្អ.. ។ បើសិនជាសានាចក្រត្រូវបានពង្រឹង នោះវាត្រូវតែមាន បើសិនចំណេះវិជ្ជានៃដំណឹងល្អ ត្រូវបានពង្រីកនៅក្នុងចំណោមសមាជិកភាពនៃសាសនាចក្រ នោះវាត្រូវតែមាន បើសិនជាផ្លូវវិញ្ញាណនៃប្រជាជនរបស់យើងបានប្រសើរ វាត្រូវតែមាន —បន្ទាប់មកសាលាថ្ងៃអាទិត្យនឹងបានក្លាយជាមានប្រសិទ្ធិភាពច្រើនទៅទៀត ។"
( គរដឹន ប៊ី ហ៊ីងឃ្លី "សាលាថ្ងៃអាទិត្យ ជាអ្នកផ្សព្វផ្សាយសាសនា" *អ៊ិនហ្សាញ* ខែ សីហា ឆ្នាំ1971 , 29 ។)